ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១៩៧/ ក.ប.ក /១៨

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែសីហា និងទិសដៅខែកញ្ញា ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ក្នុងខែសីហា ឆ្នាំ២០១៨នេះ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង និងអង្គភាពពាក់ព័ន្ធនានា ជាពិសេស លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី ។

ក្រោយពីរាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ ធ្វើការខុសច្បាប់ក្នុងប្រទេសថៃចាប់ពីដើមខែកក្កដា ឆ្នាំ២០១៨មក ។ ទោះបីជារាជរដ្ឋាភិបាល បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណមួយលានប្រាំបីម៉ឺននាក់ (តាមរបាយការណ៍ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ដែលបានបញ្ចប់នៅដើមខែកក្កដា ឆ្នាំ២០១៨ កន្លងទៅ នៅក្នុងប្រទេសថៃយ៉ាងណាក្តី ក៏នៅតែមានពលករជាច្រើនទៀត ដែលមិនទទួលបានភាពស្របច្បាប់ពេញលេញ នឹងនៅតែជួបប្រទះនឹងហានិភ័យ ដោយការបញ្ជូនត្រឡប់ ឬត្រូវបានឃាត់ខ្លួន ដាក់ទោសទណ្ឌ ឬ រងការកេងប្រវ័ញ្ចគ្រប់ទម្រង់ នាំឲ្យខាតបង់ប្រាក់កាស និងពេលវេលា។ យុវជនមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ចផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន តែមិនពិតប្រាកដ ជាដើម។

ថ្មីៗនេះ រូបភាពនៃអំពើធ្វើអាជីវកម្មផ្លូវភេទ ក៏កើតឡើងនូវសកម្មភាពផលិត និងចែកចាយរូបភាពអាសអាភាសយ៉ាងអាណាធិបតេយ្យ ក្នុងគោលដៅពាណិជ្ជកម្មផ្លូវភេទ នៅតាមតំបន់ទេសចរណ៍ និងអភិវឌ្ឍន៍ថ្មី ដូចជានៅខេត្តព្រះសីហនុ រាជធានីភ្នំពេញ និងសាយភាយទៅតាមទីជនបទមួយចំនួនទៀត។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

# ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

## ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១-ច្បាប់ គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ៖

ក.១.១-សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.១.២-សន្ធិសញ្ញាកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
  - ស្តីពី"បត្យាប័ន"
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - ស្តីពី "បញ្ជូនទណ្ឌិត"
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.១.៣-អនុស្សរណៈកំពុងរៀបចំ៖

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ក.១.៤-បទដ្ឋានគតិយុត្តិ កំពុងរៀបចំ៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តលក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ"។
- ក្រសួងអប់រំ យុវជន និងកីឡា៖ ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រិត្យ ស្តីពីរបេបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ Putha

និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ.ការបង្ការ ទប់ស្កាត់

### ខ.១-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

រដ្ឋបាលខេត្តចំនួន២ ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន ៧.១០៦ក្បាល (បាត់ដំបងចំនួន ៥.១០២ក្បាល បន្ទាយមានជ័យ ២.០០៤ក្បាល) ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែសីហា ឆ្នាំ២០១៨នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" ដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន ៣.៩៦០លើក មានអ្នកចូលរួមសរុបចំនួន ២៣១.៩០៧នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួន ២៣៦.០៦០នាក់) ថយចុះចំនួន ៤.១៥៣នាក់ ស្មើនឹង១.៧៩% ក្នុងនោះស្ត្រីមានចំនួន ១២២.០៧៨នាក់។ (ឧបសម្ព័ន្ធទី១)

### ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- លេខាធិការដ្ឋានគ.ជ.ប.ជ បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន ៤៦លើក (ខេត្តកោះកុង ៣៤លើក និងខេត្តសៀមរាប ១២លើក)។
- ខេត្តបាត់ដំបង អង្គការ **Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុក ៥១នាក់ ស្រី១៦នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

### ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

#### ខ.៤.១-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការ ទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៥៩៣គោលដៅ មានមនុស្សចំនួន ២.២៥៦នាក់ (ស្រី ១.៧៩១នាក់) កម្លាំងជំនាញអនុវត្តន៍ នៃស្នងការដ្ឋាននគរបាលខេត្តៈ (តាកែវ កែប សៀមរាប មណ្ឌលគិរី ស្ទឹងត្រែង ព្រះសីហនុ កោះកុង ក្រចេះ ឧត្តរមានជ័យ កំពង់ធំ និងរតនគិរី)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ សរុបចំនួន ៧៥គោលដៅទូទាំងរាជធានី-ខេត្ត។

- ការល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន ៣៣លើក ខេត្តអនុវត្តមាន៖ (ស្វាយរៀង ព្រះវិហារ ឧត្តរមានជ័យ ស្ទឹងត្រែង និងព្រៃវែង)។
- ខេត្តកំពង់ចាម ស្នងការដ្ឋាននគរបាល បានចុះចលនាដាក់បណ្តាញភ្នាក់ងារចំនួន ៥៩នាក់ ដើម្បីធ្វើការពាក់ព័ន្ធសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី និងបណ្តាញសហគមន៍។
- ខេត្តសៀមរាប
    - មន្ទីរទេសចរណ៍ បានចុះត្រួតពិនិត្យនៅតាមបណ្តាសេវាកម្មសណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ ដើម្បីជំរុញឲ្យម្ចាស់អាជីវកម្មបន្តអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់ទេសចរផ្លូវភេទ និងការជួញដូរមនុស្ស និងបន្តបិទផ្សាយហាមមិនឲ្យក្មេងអាយុក្រោម១៨ឆ្នាំ ចូលទៅមណ្ឌលកម្សាន្តដោយគ្មានអាណាព្យាបាលទៅជាមួយ។
    - រដ្ឋបាលក្រុងសៀមរាប បានធ្វើការដឹកនាំ និងជំរុញឲ្យមន្ត្រីក្រោមឱវាត ចុះពិនិត្យតាមបណ្តាភូមិ និងប៉ុស្តិ៍រដ្ឋបាលទាំង១២សង្កាត់ ដែលមានប្រជាការពារសរុប ៧១ក្រុម ស្មើនឹង១១១គោលដៅ មានមនុស្សសរុបចំនួន ២.៥៣២នាក់ លើ៩៩ភូមិ។

**ខ.៥-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់**

ខ.៥.១-<u>វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក</u>

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុកទៅក្រៅប្រទេសទូទាំងរាជធានី-ខេត្ត សរុបចំនួន៣១១.៧៨៦នាក់ (ស្រី១៥៩.១២៤នាក់) អនីតិជន១១.០២០នាក់ (ស្រី៤.២៥២នាក់) ក្នុងនោះស្របច្បាប់ចំនួន១៩៥.៣៧៦នាក់ (ស្រី៩០.៤៦៥នាក់) អនីតិជន២.១០០នាក់ (ស្រី៩៤០នាក់) មិនស្របច្បាប់ចំនួន១១៦.៤១០នាក់ (ស្រី៦៨.៦៥៩នាក់) អនីតិជន៨.៩២០នាក់ (ស្រី៣.៣០២នាក់) ប្រៀបធៀបនឹងខែមុន ថយចុះចំនួន៤៤.០៦៧នាក់ ស្មើនឹង១០.៨៥%។

ខ.៥.២-<u>ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន</u>

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៦៤លើក មនុស្សចំនួន ២១៨នាក់ (ស្រី ១០០នាក់ កុមារ ០៣នាក់)។ ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន ៤៣លើក មនុស្ស ៨៤នាក់ ស្រី ៥២នាក់ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ២១លើក មនុស្ស ១៣៤នាក់ (ស្រី ៤៨នាក់ កុមារ ០៣នាក់)។

*<u>របាយការណ៍ស្ថានភាព</u>* ៖

- **អគ្គបញ្ជាការដ្ឋានទីចាត់ការ ការងារព្រំដែន** បានទទួល និងសម្ភាសន៍ពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន ២.០៤៤នាក់ ស្រី ៦៧៧នាក់ អនីតិជន ១៥១នាក់ ក្នុងនោះមាន៖
    - ច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ១.៩៨៤នាក់ ស្រី ៦៥៤នាក់ អនីតិជន ១៤៨នាក់
    - ច្រកអន្តរជាតិដូង ចំនួន ៦០នាក់ ស្រី ២៣នាក់ អនីតិជន ០៣នាក់។
- ក្រុមការងារអនុវត្តច្បាប់បានរាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន ៤២នាក់ (ស្រី១១នាក់) ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែ មុននឹងបញ្ជូនមកកម្ពុជាវិញ។
- ខេត្តបន្ទាយមានជ័យ អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព "និរទេស" តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុប ៦២ជើង/រថយន្ត មានមនុស្សចំនួន ១.៩៣៨នាក់

(ស្រី ៦៧៤នាក់) ក្នុងនោះកុមារចំនួន ១៦៦នាក់ (កុមារី ៦៧នាក់)។ បើប្រៀបធៀបនឹងខែកក្កដា ឆ្នាំ ២០១៨ គឺមានការថយចុះចំនួន ៩៧៨នាក់។

- ខេត្តបាត់ដំបង បានទទួលពលករខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកកម្ពុជាវិញសរុបចំនួន ០៤លើក មនុស្សចំនួន ៦០នាក់ ស្រី ២១នាក់ កុមារី ១១នាក់។
- ដោយឡែក យោងរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបង្ហាញថា មានជនបរទេស ដែលល្មើសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១-ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន ៥២លើក មនុស្សចំនួន ១២៤នាក់ ស្រី១៤នាក់ មាន២១សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋាន ចំនួន ៣៦លើក មនុស្ស ៦៤នាក់ ស្រី ០៨នាក់ មាន១៨សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន ១៦លើក មនុស្សចំនួន ៦០នាក់ ស្រី ០៦នាក់ មាន១៩សញ្ជាតិ។

២-បទល្មើសស្នាក់នៅខុសច្បាប់ ៖

- ករណីហួសទិដ្ឋាការ មនុស្សចំនួន ០១នាក់ សញ្ជាតិកូរ៉េ។
- ករណីលួចឆ្លងដែនខុសច្បាប់ មនុស្សចំនួន ០៤នាក់ ស្រី ០១នាក់ សញ្ជាតិវៀតណាម។

៣-ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ៖

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជា មិនប្រក្រតីពីជនបរទេសបែបអន្តោប្រវេសន៍ សរុបចំនួន ១៤៦គ្រួសារ មនុស្សចំនួន១២៣នាក់ ស្រី៥៦នាក់ សញ្ជាតិវៀតណាម។

៤-ការគ្រប់គ្រងជនបរទេសវិនិយោគឯកជន ៖

- ក្រុមការងារចម្រុះអធិការកិច្ចហត្ថពលកម្មបរទេស បានចុះត្រួតពិនិត្យតាមសហគ្រាស និងគ្រឹះស្ថាននានា តាមបណ្តារាជធានី-ខេត្ត បានចំនួន **២៥៧**គោលដៅ ពលករសរុបចំនួន **១.៤០៧**នាក់ ស្រី **៤៧៨**នាក់ មាន៣០សញ្ជាតិ មានប័ណ្ណការងារចំនួន **១.៣៩២**នាក់ និងគ្មានប័ណ្ណការងារចំនួន **១៥**នាក់ ក្នុងនោះបានផាកពិន័យចំពោះជនបរទេសដែលពុំមានប័ណ្ណការងារចំនួន **១៥**នាក់ ទឹកប្រាក់បានចំនួន **៧.៥០០.០០០**រៀល។

### ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនឹងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន ១១៥គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរចំនួន៥នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេស តាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន ៨ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត (រាជធានីភ្នំពេញ បាត់ដំបង កំពង់ធំ កណ្ដាល មណ្ឌលគិរី ព្រះវិហារ ព្រៃវែង និងខេត្តត្បូងឃ្មុំ។

គ.១-ការងារអនុវត្តច្បាប់

គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) មានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និង ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ បានចំនួន ១៤/១១ករណី (បើប្រៀបធៀបនឹងខែមុនកើនឡើង ០៣ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូន ទៅសាលាដំបូងចំនួន ១៤នាក់ (ស្រី ០៣នាក់) ជនសង្ស័យជាអនីតិជន ០១នាក់។ យើងបានសង្គ្រោះជនរងគ្រោះ ចំនួន ១៣នាក់ មានអាយុក្រោម១៥ឆ្នាំ ១២នាក់ និងអាយុ១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ឲ្យគ្រួសារទាំងអស់)។

១.អំពើជួញដូរមនុស្សៈ

បង្ក្រាបបាន០៣/០៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់ (ស្រី ០២នាក់) និងសង្គ្រោះជនរងគ្រោះ ចំនួន ០១នាក់ មានអាយុ១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ឲ្យគ្រួសារ)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោមៈ

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ០២ |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ |
| *សរុប* | *០៣ ករណី* | *០៣ នាក់* |

២.អំពើធ្វើអាជីវកម្មផ្លូវភេទៈ

បង្ក្រាបបាន ១១/០៨ករណី (កើនឡើង០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់ (ស្រី០១នាក់) ជនសង្ស័យជាអនីតិជន ០១នាក់ និងសង្គ្រោះជនរងគ្រោះចំនួន ១២នាក់ មានអាយុក្រោម១៥ឆ្នាំ ១២នាក់ (ប្រគល់ ឲ្យឲ្យគ្រួសារទាំងអស់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោមៈ

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ |
| -អំពើអាសប្រធាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ |
| *សរុប* | *១១ នាក់* | *១១ នាក់* |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ

ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និង ជនសង្ស័យរងគ្រោះ

- យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយ អំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការ ដៃគូ មានចំនួន ៦០នាក់ ស្រី ៤២នាក់ មកពី ៖

- ប្រទេសម៉ាឡេស៊ី ចំនួន ២៩នាក់ (ស្រី ១៣នាក់)
- ប្រទេសចិន ចំនួន ២៧នាក់ (ស្រី ២៧នាក់)
- ប្រទេសឥណ្ឌូនេស៊ី ចំនួន ០២នាក់
- ប្រទេសសឹង្ហបុរី ចំនួន ០១នាក់ (ស្រី ០១នាក់)
- ប្រទេសអារ៉ាប៊ីសាអូឌីត ចំនួន ០១នាក់ (ស្រី ០១នាក់)។

*ស្ថាប័ន-អង្គភាពអនុវត្តមាន ៖*

- អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) បានទទួលពលករខ្មែររងគ្រោះចំនួន ២៨នាក់ (ស្រី ២៥នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី ១៩នាក់ ចិន ០៨នាក់ និងប្រទេសថៃ ០១នាក់ តាមការសម្ភាសន៍បានឲ្យដឹងថា៖
  - ទៅតាមរយៈមេខ្យល់ ចំនួន ១៧នាក់(ចិន ០៨នាក់ ម៉ាឡេស៊ី ០៨នាក់ និងថៃ ០១នាក់)
  - ទៅដោយខ្លួនឯង ចំនួន ០៤នាក់(ម៉ាឡេស៊ី)
  - ទៅតាមរយៈក្រុមហ៊ុន ចំនួន ០៧នាក់(ម៉ាឡេស៊ី)។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ៤០នាក់ (ស្រី ៣៣នាក់) មានដូចជា: ប្រទេសចិន ១៨នាក់ (ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ) និងប្រទេសម៉ាឡេស៊ី ២២នាក់ (ករណីជួញដូរកម្លាំងពលកម្ម) ដោយមានការសហការពីអង្គការសម្ព័ន្ធចាប់ដៃ អង្គការ IOM អង្គការរតនៈអ៊ិនធើណេសិនណល និងអង្គការ (IJM)។

**ឃ.៣-ការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅទទួលសេវាស្នាក់នៅ (រយៈពេលវែង-ខ្លី) និងស្តារនីតិសម្បទា**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិម្បទាចំនួន ៥៥នាក់ (ស្រី ៤២នាក់) ក្នុងនោះមាន៖

- បានធ្វើការសម្ភាស និងបញ្ជូនជនរងគ្រោះទាំង៤០នាក់ (ស្រី ៣៣នាក់) ទៅទទួលសេវាបន្តនៅអង្គការដៃគូមានដូចជា: អង្គការសម្ព័ន្ធចាប់ដៃ អង្គការIOM អង្គការរតនៈអ៊ិនធើណេសិនណល អង្គការបេសកម្មយុត្តិធម៌អន្តរជាតិ(IJM) អង្គការសួននៃក្តីសង្ឃឹមកម្ពុជា និងអង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ(CWCC)។
- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានបញ្ជូនជនរងគ្រោះដែលនិរទេសពីប្រទេសថៃចំនួន ១០នាក់ (បុរស០១នាក់ ស្ត្រី០១នាក់ កុមារា០៥នាក់ កុមារី០៣នាក់) ទៅទទួលសេវាបន្តនៅ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ០៦នាក់ អង្គការតំណក់ទឹក០២នាក់ និងអង្គការភឿន០២នាក់ មុនពេលត្រឡប់ទៅផ្ទះវិញ។
- មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ បានធ្វើការពិគ្រោះយោបល់ និងបញ្ជូនស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ០៤នាក់ ទៅស្តារនីតិសម្បទានៅមណ្ឌលរដ្ឋ និងអង្គការដៃគូក្នុងនោះមាន មន្ទីរស.អ.យរាជធានី០២នាក់ និងមន្ទីរស.អ.យ ខេត្តសៀមរាប ០២នាក់។
- អង្គការក្តីសង្ឃឹម និងយុត្តិធម៌ បានទទួលស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ០១នាក់ ស្នាក់នៅ និងទទួលសេវានៅក្នុងមណ្ឌលរបស់អង្គការ។

ឃ.៤-ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការយុត្តិធម៌ និងក្តីសង្ឃឹម បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍វិញ សរុបចំនួន ០៦នាក់ (ស្ត្រី០៤នាក់) ជាករណីជួញដូរកម្លាំងពលកម្ម។

## II. ការលើកកម្ពស់សមត្ថភាព

### ក. ក្នុងប្រទេស

ក.១-ការងារបណ្តុះបណ្តាល

- ខេត្តសៀមរាប បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពដល់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើការរៀបចំផែនការសកម្មភាពរយៈពេល៥(២០១៩-២០២៣) អ្នកចូលរួមចំនួន៨៥នាក់ ស្រី៤៤នាក់។

ក.២-សិក្ខាសាលា

- ខេត្តបាត់ដំបង បានរៀបចំសិក្ខាសាលា ស្តីពីកិច្ចសហការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលមានសមាសភាពចូលរួមៈ អភិបាលរងក្រុង/ស្រុក ស្នងការដ្ឋាននគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត មន្ទីរទេសចរណ៍ខេត្ត មន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្ត មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត អយ្យការអមសាលាដំបូងខេត្ត មជ្ឈមណ្ឌលការងារ អង្គការ IJM អង្គការ World Vision លោកមេឃុំ និង គ.ក.ន.ក និងអង្គការ ស្ថាប័នពាក់ព័ន្ធ សរុបចំនួន ៨៧នាក់ ស្រី៤៩នាក់។

ក.៣-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៥៨លើក មានអ្នកចូលរួមសរុប **៩២៥**នាក់ មានស្រី **៣៧០**នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន **២៧**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០៣លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន ០៤លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **២៤**លើក ។ (ឧបសម្ព័ន្ធទី២)

### ខ. ក្រៅប្រទេស

ខ.១-កិច្ចប្រជុំ

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៧ បាលីប្រូសេស (Bali Process) ស្តីពីការរត់ពន្ធ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធ ប្រព្រឹត្តិទៅ

នៅកោះបាលី ប្រទេសឥណ្ឌូណេស៊ី ដោយមានការចូលរួមពីថ្នាក់រដ្ឋមន្ត្រីតំណាងប្រទេសចំនួន ២៦ នៅជុំវិញពិភពលោក។

## III. ការសន្និដ្ឋានវាយតម្លៃ

### ក. ចំណុចខ្លាំង

- ការគាំទ្ររបស់រាជរដ្ឋាភិបាល ចំពោះសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ដែលត្រូវបានចាត់ទុកថាជាការងារអាទិភាពមួយដ៏សំខាន់ដែលត្រូវយកចិត្តទុកដាក់ បានបើកផ្លូវឲ្យមានដំណោះស្រាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយថ្នាក់តំបន់ និងសកលលោក។
- ក្រសួងស្ថាប័នពាក់ព័ន្ធនានា ក្នុងរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ គោលការណ៍ ផែនការសកម្មភាព និងបទដ្ឋានការងារជាច្រើន ដើម្បីរួមគ្នាធ្វើសកម្មភាពបង្ការ ទប់ស្កាត់ ការពារ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឲ្យកាន់តែមានប្រសិទ្ធភាព។
- កិច្ចសហការ និងការឯកភាពគ្នាក្នុងការធ្វើប្រតិបត្តិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានផ្តល់នូវភាពខ្លាំងក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស ឲ្យបានជោគជ័យ ។
- អនុសាសន៍ដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងវិធានការ ០៦ចំណុច របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតែជាត្រីវិស័យសម្រាប់តម្រង់ទិសការងារគណៈកម្មាធិការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។
- ការចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិនានា ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។ បានផ្តល់នូវការយោគយល់គ្នា និងកិច្ចសហការល្អ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាបានដោយរលូន ។
- យន្តការជាតិ ដែលមានរចនាសម្ព័ន្ធទូលំទូលាយ ច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងការចូលរួមពីអង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិដទៃទៀត បានក្លាយជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។

### ខ. ចំណុចខ្វះខាត និងភាពប្រឈម

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន នៅមិនទាន់មានកិច្ចសហការល្អគ្រប់គ្រាន់ មិនទាន់បើកទូលាយ មិនទាន់បង្កលក្ខណៈ និងផ្តល់ធនធានសម្រាប់ប្រតិបត្តិការ និងមិនទាន់មានលក្ខណៈជាប្រព័ន្ធ ដែលអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហាបាន ក្រសួង ស្ថាប័ន ឬអង្គភាពជាសមាជិកខ្លះ មិនបានផ្តល់របាយការណ៍ដែលបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័ន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបាន និងកំពុងប៉ះពាល់ដល់ដំណើរការនៃការអភិវឌ្ឍន៍ជាតិ តាមវិស័យទាំងនោះឡើយ។

- មន្ត្រីទទួលបន្ទុកនៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមិនទាន់យល់ច្បាស់ពីការងារ និងតួនាទីភារកិច្ច ជាសមាជិកគណៈកម្មាធិការជាតិ ដែលត្រូវរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗ។
- របាយការណ៍ដែលផ្ញើមកអគ្គលេខាធិការដ្ឋាន តែងតែយឺតយ៉ាវ មិនទាន់ពេលវេលា ។

## គ.សំណូមពរ

- ត្រូវការការជំរុញ និងពង្រឹងបន្ថែមពីប្រធានស្ថាប័នជាសមាជិក គ.ជ.ប.ជ គ្រប់កម្រិត អំពីរបៀបរបបការងារ ដើម្បីពង្រឹងទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងការធ្វើរបាយការណ៍ ស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូចមានចែងក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងអនុក្រឹត្យ និងសេចក្តីសម្រេចពាក់ព័ន្ធនឹងតួនាទីភារកិច្ចរបស់ក្រសួងស្ថាប័នជាសមាជិក ។
- ត្រូវការវគ្គបណ្តុះបណ្តាលដល់មន្ត្រីជួរមុខ និងមន្ត្រីអនុវត្តន៍ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ត្រូវការឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ គួបផ្សំនឹងការគាំទ្រធនធានឲ្យបានសមស្រប ដើម្បីសម្រួលដល់ដំណើរការកិច្ចប្រតិបត្តិការ។

## ឃ.សន្និដ្ឋាន

- អាស្រ័យដោយមានការគាំទ្រ និងយកចិត្តទុកដាក់យ៉ាងខ្លាំងពីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានធ្វើឲ្យសភាពការណ៍សន្តិសុខ សុវត្ថិភាព របស់ប្រជាពលរដ្ឋកម្ពុជាកាន់តែត្រូវបានយកចិត្តទុកដាក់ប្រសើរឡើង ។ ប្រជាជនគ្រប់រូប ត្រូវបានទទួលការការពារយ៉ាងហ្មត់ចត់ រួមទាំងការគិតគូពីរបបសន្តិសុខសង្គម សម្រាប់ពលករ ពលការិនី មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ទើបធ្វើឲ្យស្ថានភាពជួញដូរមនុស្ស នៅកម្ពុជាមានការប្រែប្រួលតិចតួច និងអាចគ្រប់គ្រងបាន ។
- រាជរដ្ឋាភិបាលកម្ពុជាមានច្បាប់ គោលនយោបាយគ្រប់គ្រាន់ និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការគោរពសិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋ ការពារសុវត្ថិភាព ពីភាពរងគ្រោះ ជាពិសេស ដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។
- ការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាយន្តការជាតិ គឺជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលមានសក្តានុពលទូលំទូលាយ ប្រកបដោយឆន្ទៈមោះមុត មានការប្តេជ្ញាចិត្តខ្ពស់ មានកិច្ចសហប្រតិបត្តិការល្អ និងមានសមត្ថភាពដោះស្រាយរាល់បញ្ហា ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស ។
- ល្បិចកលក្នុងការប្រព្រឹត្តបទល្មើស មានការប្រែប្រួល បត់បែន កាន់តែស្មុគស្មាញ និងពិបាកកំណត់។

ទោះបីយ៉ាងនេះក្តី ក៏មន្ត្រីអនុវត្ត កាន់តែមានជំនាញ មានបទពិសោធន៍កាន់តែស៊ីជម្រៅ និងកាន់តែមានការចូលរួម និងកិច្ចសហការល្អពីអ្នកពាក់ព័ន្ធ ជាតិ និងអន្តរជាតិ ។

- ប្រជាពលរដ្ឋកាន់តែមានការយល់ដឹងច្រើនពីអំពើជួញដូរមនុស្ស និងមានការប្រុងប្រយ័ត្នចំណែកជនរងគ្រោះ ក៏មានបទពិសោធន៍កាន់តែច្រើន។

ទោះបីជាយ៉ាងនេះក្តី ប្រភេទបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សថ្មីៗ បានកើតមានជាបន្តបន្ទាប់ ដែលចាំបាច់ត្រូវតែបន្តការយកចិត្តទុកដាក់ដោះស្រាយជាបន្ទាន់។

## IV. **ទិសដៅខែកញ្ញា ឆ្នាំ២០១៨**

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ផ្ទៃក្នុងជាតិ ប្រទេសពាក់ព័ន្ធ និងជាមួយអន្តរជាតិ ដើម្បីឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ការពារ និងបង្ក្រាប ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងការអនុវត្តច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការនាំទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. សម្រេចបញ្ចប់លើសេចក្តីព្រាង និងប្រកាសដាក់ឲ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ២០១៩-២០២៣ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៤. ចុះពិនិត្យ ស្ថានភាពប្រែប្រួល និងចំណុចសេសសល់ លើការងារលើកកម្ពស់សុវត្ថិភាពពលករនៅក្រៅប្រទេស ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួល។

៥. ជំរុញការកសាង អនុស្សរណៈ ឬកិច្ចព្រមព្រៀង ស្តីពីកិច្ចការពារសុវត្ថិភាពពលករក្នុងវិស័យនេសាទ។

៦. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៧. បន្តពង្រឹងការងារបង្ការ ទប់ស្កាត់ តាមរយៈការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី និងជំរុញការអនុវត្ត គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រីអនុវត្តន៍នៅតាមបណ្តាក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងមន្ត្រីស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

១០.ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១.បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលកររទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" និងការរៀបចំយន្តការទទួលពលករ នៅមណ្ឌលទទួលពលករប៉ោយប៉ែត និងត្រៀមរៀបចំបន្តតាមគោលដៅច្រកទ្វារសំខាន់ៗដទៃទៀត (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ )។

១២.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមកក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១៣.រៀបចំវេទិកាអន្តរសាសនា ប្រឆាំងអំពើជួញដូរមនុស្ស។

១៤.រៀបចំទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១៥.បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ។

១៦.បន្តអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ **ប្រមុខរាជរដ្ឋាភិបាល និងសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ជំរុញការសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានលំហូរពលករឆ្លងកាត់ និងមានការបញ្ជូនត្រឡប់ពីប្រទេសថៃ ដោយរៀបចំយន្តការអន្តរស្ថាប័ន ដែលមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារសម្រន់ សម្រាប់មនុស្សចាស់ កុមារ ទារក ការផ្តល់ប្រឹក្សា ការផ្តល់ព័ត៌មានអំពីការងារ ឬសេវាច្បាប់ ទីកន្លែងសម្រាក ឬស្នាក់នៅបណ្តោះអាសន្ន សម្របសម្រួលរកមធ្យោបាយធ្វើដំណើរ ទទួលបណ្តឹង ឬសាកសួរព័ត៌មានអំពីភាពរងគ្រោះ ស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។ tha

ថ្ងៃ សុក្រ ៣ កើត ខែ មិគសិរ ឆ្នាំ ច ......សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១២ ...ខែ ធ្នូ ...ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែសីហា ឆ្នាំ២០១៨**

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំ មានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 24 លើក | 702 នាក់ | 482 នាក់ |
| 2 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 214 លើក | 17,740 នាក់ | 7,397 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការការប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស និងបញ្ជ្រាបតាមកិច្ចប្រជុំនានា ដល់អាជ្ញាធរ មូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក និងមន្ទីរអប់រំយុវជន និងកីឡា | 22 លើក | 5,514 នាក់ | 3,220 នាក់ |
| 3 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 440 លើក | 26,473 នាក់ | 14,703 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 234 លើក | 9,637 នាក់ | 5,274 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 75 លើក | 3,340 នាក់ | 1,663 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅតាមវិទ្យាល័យ អនុវិទ្យាល័យទាំង២០ ទូទាំងខេត្តពោធិ៍សាត់ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 207 លើក | 17,518 នាក់ | 9,198 នាក់ |
| 5 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយ ស្តីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក និងស្នងការដ្ឋាននគរបាលខេត្ត | 825 លើក | 53,457 នាក់ | 29,281 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 140 លើក | 7,340 នាក់ | 3,606 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តស្វាយរៀង | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម សង្ស័យថាមានពាក់ព័ន្ធបទល្មើសផ្លូវភេទដូចជា (ខារ៉ាអូខេ ផ្ទះសំណាក់ ម៉ាស្សាកោសជប់ កាស៊ីណូ ផ្ទះលក់កាហ្វេ វីដេអូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 12 លើក | 63 នាក់ | 52 នាក់ |
| 7 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ ប្រជាពលរដ្ឋ នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត។ | ក្រុមការងារអធិការនគរបាល ក្រុងស្រុក | 18 លើក | 847 នាក់ | 507 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ នៅតាមគ្រឹះស្ថានសិក្សា តាមកិច្ចប្រជុំ ឬក្នុងកម្មវិធីផ្សេងៗ។ | មន្ទីរអប់រំយុវជន និងកីឡាខេត្ត | 24 លើក | 5,831 នាក់ | 2,214 នាក់ |
| 8 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយ បានបញ្ជ្រាបក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 23 លើក | 948 នាក់ | 368 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយ សុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត | 149 លើក | 6,433 នាក់ | 994 នាក់ |
| 9 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 501 លើក | 17,681 នាក់ | 8,915 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងផ្សព្វផ្សាយច្បាប់ ការងារ ស្តីពីការជួញដូរមនុស្ស នៅតាមរោងចក្រ សហគ្រាស ដល់កម្មករ និយោជិក។ | ស្នងការដ្ឋាននគរបាលខេត្ត រដ្ឋបាលស្រុក និងមន្ទីរការងារខេត្ត | 626 លើក | 32,125 នាក់ | 16,983 នាក់ |
| 10 | ខេត្តរតនៈគិរី | វេទិកាសាធារណៈ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 14 លើក | 939 នាក់ | 387 នាក់ |
| | | ផ្សព្វផ្សាយ ទៅដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្មនានា ក្នុងខេត្ត ឲ្យអនុវត្តតាមច្បាប់ការងារ ស្តីពីការបង្ការ ទប់ស្កាត់ ការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់។ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | 4 លើក | 34 នាក់ | 22 នាក់ |
| 11 | ខេត្តកំពង់ធំ | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 3 លើក | 527 នាក់ | 333 នាក់ |
| 12 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 25 នាក់ | 16 នាក់ |
| 13 | ខេត្តឧត្តរមានជ័យ | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 5 លើក | 2,144 នាក់ | 1,560 នាក់ |
| 14 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់ ដល់សិស្សានុសិស្ស ប្រជាពលរដ្ឋ និងមន្ត្រីរាជការ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 14 លើក | 1,481 នាក់ | 947 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 15 | ខេត្តសៀមរាប | ផ្សព្វផ្សាយអំពីគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាប ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ប្រជាពលរដ្ឋ និងមន្ត្រីរាជការ អាជ្ញាធរក្រុង-ស្រុក។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរនានា និង ស្នងការដ្ឋាននគរបាលខេត្ត | 343 លើក | 19,517 នាក់ | 12,770 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ និងមន្ត្រីរាជការ អាជ្ញាធរក្រុង-ស្រុក។ | | 42 លើក | 1,591 នាក់ | 1,186 នាក់ |

សកម្មភាពសរុបចំនួន: 3,960 លើក

មនុស្សសរុបចំនួន: 231,907 នាក់

ស្រីសរុបចំនួន : 122,078 នាក់

# ឧបសម្ព័ន្ធទី២

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៥៨លើក) មនុស្ស ចំនួន ៩២៥នាក់ (ស្រី ៣៧០នាក់)

<table>
<tr><th>ស្ថាប័ន<br>សម្របសម្រួល</th><th>សកម្មភាព</th></tr>
<tr><td>គណៈកម្មាធិការជាតិ<br>គ.ជ.ប.ជ</td><td>សម្របសម្រួលចំនួន២៧លើក អ្នកចូលរួមសរុបចំនួន ១៧៦នាក់ (ស្រី០៤នាក់)<br>❖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពី៖<br>○ ករណីស្ត្រីពពោះជំនួស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>○ ក្រុមការងារយេនឌ័រ ប្រព្រឹត្តទៅនៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>○ ការរៀបចំវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី២ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>○ បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារទទួលពលករនៅប៉ោយប៉ែត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានអញ្ជើញជាអធិបតី៖<br>○ ក្នុងសិក្ខាសាលាបញ្ចប់ របស់ក្រុមការងារបច្ចេកទេសកម្ពុជា នៃកម្មវិធីអូស្ត្រាលី-អាស៊ី ដើម្បីប្រឆាំងការជួញដូរមនុស្ស (AAPTIP) នៅសណ្ឋាគារភ្នំពេញ ។<br>○ ក្នុងកិច្ចប្រជុំពិភាក្សា ស្តីពីការពង្រឹងកិច្ចសហការ ការងាររវាងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូរក្នុងការជួយដល់ពលករកម្ពុជាដែលត្រូវបញ្ជូនត្រលប់មកពីប្រទេសថៃ នៅខេត្តបន្ទាយមានជ័យ ។<br>○ និងធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីការរៀបចំផែនការសកម្មភាពរយៈពេល១ឆ្នាំ និងរយៈពេល៥ឆ្នាំ ដល់សមាជិកលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំសាលាខេត្តសៀមរាប ។<br>○ និងថ្លែងមតិបើកអង្គសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម នៅសាលប្រជុំសាលាខេត្ត បាត់ដំបង ដែលមានសមាសភាពចូលរួមមានចំនួន១២២រូប ។<br>❖ ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត អគ្គលេខាធិការ គ.ជ.ប.ជ<br>- បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅរៀងរាល់ព្រឹកថ្ងៃច័ន្ទ នៃសប្តាហ៍នីមួយៗ ។<br>១.<u>ក្រុមជំនួយការបង្ការ ទប់ស្កាត់៖</u><br>- ឯកឧត្តម អគ្គលេខាធិការរងបានដឹកនាំសមាជិកក្រុមទាំងអស់ប្រជុំពិភាក្សាផ្ទៃក្នុងក្រុម អំពីយុទ្ធសាស្ត្របង្ការ ទប់ស្កាត់។</td></tr>
</table>

- បានពិនិត្យ និងតាមដានលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ មានចំនួន១៦រាជធានី-ខេត្ត ដែលគ្មានសកម្មភាពផ្សព្វផ្សាយការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងសកម្មភាពប្រជុំនានា។

**២-ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ:**

- នៅគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានធ្វើការសម្ភាសន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅប្រទេសចិនចំនួន០៤នាក់ ដែលទើបបញ្ជូនត្រឡប់មកកម្ពុជាវិញ ក្នុងនោះមានខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ ខេត្តកំពត និងរាជធានីភ្នំពេញ ហើយកំពុងស្នាក់នៅអង្គការចាប់ដៃ ។
- ស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស ។

**៣-ក្រុមជំនួយកិច្ចការអនុវត្តច្បាប់:**

- បានទំនាក់ទំនង និងជំរុញក្រុមការងារយុត្តិធម៌ ដើម្បីស្រង់យកចំនួនតួលេខជម្រះក្តីពីក្រសួងយុត្តិធម៌។

**៤-ក្រុមជំនួយកិច្ចការយុត្តិធម៌:**

- លោកឧត្តមសេនីយ៍ត្រី ស៊ុន ប៊ុណ្ណា អនុប្រធាននាយកដ្ឋានក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស គម្រោង AAPTIP កម្ពុជា លើកទី១០ ក្រោមអធិបតីភាព ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកនៃអគ្គនាយកដ្ឋានអយ្យការ និងកិច្ចការព្រហ្មទណ្ឌ ដែលមានសមាជិកចូលរួមចំនួន៤១នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។

**៥-ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ:**

- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានដឹកនាំកិច្ចប្រជុំក្រុមទី២ ដែលត្រៀមរៀបចំកម្មវិធី អន្តរសាសនាថ្នាក់ជាតិ លើកទី២ ដោយមានការចូលរួមពីសមាសភាពសរុប១៣រូប ស្រី០៤រូប នៅបន្ទប់ប្រជុំការិយាល័យលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។

**៦-ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:**

- បានស្រាវជ្រាវព័ត៌មានពាក់ព័ន្ធពលករទេសន្តរប្រវេសន៍តាមរយៈTelegram ជាលទ្ធផលបានឲ្យដឹងថា៖ កាលពីថ្ងៃសុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ បានចុះសាកសួរសុខទុក្ខ និងបានពាំនាំនូវថវិកាមួយចំនួនជូនពលការិនី ថោង ច្រឹប ដែលបានទទួលរងគ្រោះថ្នាក់ក្នុងពេលបំពេញការងារ បណ្តាលអោយបាត់បង់ម្រាមដៃចំនួន០១។
- បានទំនាក់ទំនងស្នើសុំរបាយការណ៍ស្តីពី សកម្មភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០១៨ ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ជាលទ្ធផលបានទទួលរួចហើយ ក៏បានប្រគល់ជូនការិយាល័យសរុប ផែការរបស់អគ្គលេខាអធិការដ្ឋាន គ.ជ.ប.ជ ឆ្នាំ២០១៨ ដើម្បីបញ្ចូលក្នុងរបាយការណ៍ឆមាសទី១រួចរាល់ហើយដែរ។
- បានចូលរួមប្រជុំពិភាក្សា អំពីការងាររៀបចំក្រុមការងារ និងយន្តការ ទទួលពលករ ពលការិនីកម្ពុជាដែលត្រូវបានបញ្ជូនពីប្រទេសថៃក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និង ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

| | |
|---|---|
| | - លោកឧត្តមសេនីយ៍ត្រី កែវ ផល្លា ចូលរួមប្រជុំកែតម្រូវផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំបន្តរបស់ក្រុមពិភាក្សាទី២ "យុទ្ធសាស្ត្របង្ការ ទប់ស្កាត់ គ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស"ជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងស្តាប់អនុសាសន៍ណែនាំ ដាក់បញ្ចូលសកម្មភាពតូចៗ បន្ថែមមួយចំនួនទៀត ដែលបំបែកចេញពីចង្កោមសកម្មភាពធំៗ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានទំនាក់ទំនងស្នើសុំទិន្នន័យពលរដ្ឋខ្មែររងគ្រោះនៅបរទេស ដែលត្រូវបានអន្តរាគមន៍ សង្គ្រោះនិងសម្របសម្រួលជួយធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញរយៈពេល ៦ខែ (ឆ្នាំ២០១៨ ឆមាសទី១) ពីនាយកដ្ឋានកិច្ចការច្បាប់ និងកុងស៊ុលនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាលទ្ធផលបានទទួលហើយ និងបានប្រគល់ជូនការិយាល័យសរុបផែនការ ដើម្បីបញ្ចូលក្នុងរបាយការណ៍ឆមាសទី១ ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រួចរាល់ហើយដែរ។<br>**៧-<u>ការងាររដ្ឋបាល៖</u>**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (១៤ច្បាប់) លិខិតចូល(០៥ច្បាប់) ,លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(០៦ច្បាប់) លិខិតចូល(២៣ច្បាប់)។<br>- ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី និងរៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំ ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកក្កដា ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ បូកសរុបរបាយការណ៍ឆមាសទី១ ឆ្នាំ២០១៨ និងរបាយការណ៍ ខែកក្កដា ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ និងប្រមូលរបាយការណ៍តាមបណ្តាអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិតី។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ |
| | សម្របសម្រួលចំនួន០៤លើក អ្នកចូលរួមសរុបចំនួន ៥១នាក់ (ស្រី១៩នាក់) |
| អគ្គនាយកដ្ឋាន<br>អន្តោប្រវេសន៍ | - អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានរៀបចំកិច្ចប្រជុំបូកសរុបការងារឆមាសទី១ និងលើកទិសដៅអនុវត្តការងារបន្តឆមាសទី២ ឆ្នាំ២០១៨។<br>- ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត សុខ ផល អគ្គនាយកអន្តោប្រវេសន៍៖<br>• បានអញ្ជើញចូលរួមក្នុងឱកាស សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុញ្ញាតឲ្យលោកជំទាវ TINA SUSAN RIDSHAW ឯក អគ្គរដ្ឋទូតចក្រភពអង់គ្លេស ទើបតែងតាំងថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម។<br>• បានជំនួបពិភាក្សាការងារជាមួយលោក JOSEPH GALOSKI តំណាងសេនានុព័ន្ធប្រចាំប្រទេសរបស់សហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា និងសហការី។<br>• បានដឹកនាំគណៈប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងជាប្រធានកុងស៊ុលអាស៊ានលើកទី២២(22nd DGICM) និងកិច្ចប្រជុំពាក់ព័ន្ធ ដែលប្រព្រឹត្តទៅថ្ងៃទី០៦ដល់១០ ខែសីហា ឆ្នាំ២០១៨។ |

| | |
|---|---|
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចាត់បញ្ជូនមន្ត្រីចូលរួមជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាលចំនួន ០២វគ្គគឺ នៅខេត្តពោធិ៍សាត់ និងបន្ទាយមានជ័យ ដែលមានសិក្ខាកាមចូលរួមចំនួន៤៧នាក់ (ស្រី១៩នាក់) ដែលរៀបចំដោយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា និងអង្គការ IOM។<br>- បានចាត់បញ្ជូនមន្ត្រី០៤រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរបស់អង្គការសម្ព័ន្ធចាប់ដៃ (រាជធានីភ្នំពេញ) ស្តីពីការពង្រឹងបណ្តាញការងារ និងកសាងសមត្ថភាពដល់អ្នកអនុវត្តការងារសង្គមកិច្ចដោយផ្ទាល់នៅកម្ពុជា។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៤លើក អ្នកចូលរួមសរុបចំនួន ៦៩៨នាក់ (ស្រី ៣៤៧នាក់)** | |
| ខេត្តកណ្តាល | - បានរៀបចំកិច្ចប្រជុំចំនួន ០៨លើក អ្នកចូលរួមចំនួន ១៧៦នាក់ ស្រី ១២០នាក់៖<br>• ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែកក្កដាចំនួន ០៦លើក អ្នកចូលរួមចំនួន ១៤២នាក់ ស្រី ៩៥នាក់។<br>• លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែសីហា ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ៣៤នាក់ ស្រី ២៥នាក់។<br>• ក្រុមការងារស្រុកអង្គស្នួលចំនួន ០២នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់ និងឯកសាក្បួននីតិវិធីប្រតិបត្តិការ របស់មន្ត្រីនគរបាលយុត្តិធម៌ រយៈពេល៣ថ្ងៃ នៅខេត្តតាកែវ។ |
| ខេត្តបាត់ដំបង | - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ០៤លើក អ្នកចូលរួមចំនួន ៩៥នាក់ ស្រី ៤០នាក់៖<br>• បានចូលរួមកិច្ចប្រជុំសម្របសម្រួលការងារគ្រប់គ្រងករណី និងសមាហរណកម្មកុមារក្នុងគ្រួសារ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត។<br>• បានចូលរួមសិក្ខាសាលាស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងបន្តការងារអនុវត្តទិសដៅ បញ្ជ្រាបយេនឌ័រ ឆ្នាំ២០១៨ ក្រោមប្រធានបទ "វត្តភាពស្ត្រីក្នុង **វិស័យនយោបាយ**" នៅសាលប្រជុំសាលាខេត្តបាត់ដំបង។<br>• បានចូលរួមជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោសុវត្ថិភាព និងការជួញដូរមនុស្ស ដែលរៀបចំឡើងដោយអង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល នៅសាលប្រជុំ សាលាស្រុកសំឡូត អ្នកចូលរួមចំនួន៤៥នាក់ ស្រី១៩នាក់។<br>• បានចូលរួមទស្សនកិច្ច ផ្លាស់ប្តូរបទពិសោធន៍រវាងស្ថាប័នបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាមួយនឹងនិយោជកក្នុងវិស័យបដិសណ្ឋារកិច្ចដែលរៀបចំឡើងដោយអង្គការទេសន្តប្រវេសន៍អន្តរជាតិ (IOM) នៅសណ្ឋាគារ (SUNWAY) អ្នកចូលរួមចំនួន៥០នាក់ ស្រី២១នាក់។ |
| ខេត្តកំពង់ឆ្នាំង | - គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក) បានរៀបចំកិច្ចប្រជុំប្រចាំខែសីហា ឆ្នាំ២០១៨ ចំនួន ០៦លើក វគ្គផ្សព្វផ្សាយបញ្ជ្រាប ស្តីពីការធ្វើចំណាកស្រុក ការជួញដូរស្ត្រី និងកុមារ កិច្ចការពារកុមារពិសេស និងតួនាទីមាតា បិតា អ្នកចូលរួមចំនួន ១២៦នាក់ ស្រី ៩២នាក់ ឧបត្ថម្ភដោយអង្គការសង្គ្រោះ កុមារកម្ពុជា(Save the Children)។ |
| ខេត្តព្រះវិហារ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំអំពីការពិភាក្សា ប្រធាន អនុប្រធាន សមាជិក ក្រុមការងារទាំង៦ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត អ្នកចូលរួមចំនួន ២២នាក់ ស្រី ០៨នាក់។ |
| ខេត្តឧត្តរមានជ័យ | - គណៈកម្មាធិការ គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររយៈពេល៨ខែ អ្នកចូលរួមចំនួន ៧៦នាក់ ស្រី ២៣នាក់។ |

| | |
|---|---|
| ខេត្តសៀមរាប | សម្របសម្រួលចំនួន ០៤លើក អ្នកចូលរួមចំនួន ២០៣នាក់ ស្រី ៦៤នាក់៖<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បាន៖<br>• រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា-សីហា ឆ្នាំ២០១៨ បានចំនួន ០២លើក នៅសាលប្រជុំលេខ១របស់សាលាខេត្ត មានអ្នកចូលរួមចំនួន ១១៣នាក់ ស្រី ៦៤នាក់។<br>• ដឹកនាំប្រធានក្រុមការងារបច្ចេកទេសទាំង៦ ចូលរួមវិធីបិទវគ្គបណ្តុះបណ្តាលលើកកម្ពស់យល់ដឹង ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន តំណាងក្រុមយុវជន ក្រុមការងារការពារកុមារ ដែលមកពីខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ មានសិក្ខាកាមចូលរួមសរុបចំនួន ៩០នាក់ នៅសណ្ឋាគារអេប្បារាផាឡែស រៀបចំដោយអង្គការទស្សនពិភពលោក។<br>- លោកស្រីលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំសម្របសម្រួលការងារគ្រប់គ្រងករណី និងសមាហរណកម្មកុមារក្នុងគ្រួសារ ប្រចាំត្រីមាសទី២ ឆ្នាំ២០១៨។ |